ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣៣០៥ សហវ.ឯក

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១០

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** ករណីសំណើសុំថវិកាចំនួន ១.៩២៦.៤១៧,៤៥ដុល្លារអាមេរិក សម្រាប់ជួសជុលស្តារឡើងវិញប្រព័ន្ធស្រោចស្រពជាំតាហ៊ីង និងខ្នារ ស្ថិតក្នុងស្រុកតំបែរ ខេត្តកំពង់ចាម ។

**យោង:** លិខិតលេខ១៥១៦ ធទឧ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៨ របស់ក្រសួងធនធានទឹកនិងឧតុនិយម ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមឯកភាពជាគោលការណ៍ផ្តល់នូវថវិកាចំនួន ១.៩២០.០០០ ដុល្លារអាមេរិក (មួយលាន ប្រាំបួនរយម្ភៃពាន់ដុល្លារអាមេរិក) ជូនក្រសួងធនធានទឹក និងឧតុនិយម សម្រាប់ស្តារឡើងវិញប្រព័ន្ធស្រោចស្រពជាំតាហ៊ីង និងខ្នារ ស្ថិតក្នុងស្រុកតំបែរ ខេត្តកំពង់ចាម ដោយប្រើប្រាស់ថវិកាក្រោមហិរញ្ញប្បទានសហប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលេខ 2585-CAM (SF) ។

ខ្ញុំសូមស្នើឯកឧត្តមមេត្តាអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ជាធរមាន ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ចាម
- មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ចាម
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com